**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០៤៣/១៩ **ក.ប**/ស.ណ.ន.ម.ហ

# សេចក្តីណែនាំ
# ស្តីពី
# ការចុះបញ្ជិកាកិច្ចសន្យាការងារជនបរទេស

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូន លោក លោកស្រីម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតជនបរទេស ដែលស្ថិតនៅក្នុងដែនអនុវត្តច្បាប់ស្តីពីការងារបានជ្រាបថា ដើម្បីអនុវត្តប្រកាសលេខ ១៩៦ ក.ប/ប្រក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេស ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ សូមលោក លោកស្រីម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតជនបរទេស ត្រូវយកចិត្តទុកដាក់អនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម៖

១-រាល់កិច្ចសន្យាការងារជនបរទេសដែលត្រូវយកមកចុះបញ្ជិកា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ (ចំនួន០៣ច្បាប់) ដោយត្រូវភ្ជាប់មកជាមួយការបកប្រែជាភាសាខ្មែរ ប្រសិនបើកិច្ចសន្យាការងារច្បាប់ដើមជាភាសាបរទេស។

២-កិច្ចសន្យាការងារជនបរទេសដែលអាចជាកិច្ចសន្យាការងារមានកំណត់ថិរវេលា (FDC) ឬកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) ត្រូវយកមកចុះបញ្ជិកានៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះសហគ្រាស គ្រឹះស្ថាននៅរាជធានីភ្នំពេញ។

ចំពោះសហគ្រាស គ្រឹះស្ថានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់រាជធានី-ខេត្ត គឺត្រូវយកមកចុះបញ្ជិកានៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត។

៣-និយោជកអាចប្រើទម្រង់កិច្ចសន្យាការងារជនបរទេសរបស់ខ្លួនបាន ដើម្បីស្នើសុំចុះបញ្ជិកា ប៉ុន្តែកិច្ចសន្យានេះ មិនត្រូវផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

៤-និយោជកត្រូវចុះបញ្ជិកាកិច្ចសន្យាការងារជនបរទេសសារជាថ្មី ស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងប្រកាសលេខ១៩៦ ខាងលើ ក្នុងករណីដែលកិច្ចសន្យានេះផុតសុពលភាព ឬមានការកែសម្រួលណាមួយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីម្ចាស់ ឬនាយក សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតបរទេស ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារនឹងអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ សុក្រ ៨រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត
- សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩